*រាជធានីភ្នំពេញ ថ្ងៃសុក្រ ទី១៩ ខែកុម្ភៈ ឆ្នាំ២០២១*

## សេចក្ដីថ្លែងការណ៍រួម

# ក្រុមសង្គមស៊ីវិលស្នើសុំឱ្យរាជរដ្ឋាភិបាលនិរាករណ៍អនុក្រឹត្យស្ដីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ

យើងខ្ញុំជាក្រុមសង្គមស៊ីវិលដូចមានរាយឈ្មោះនៅខាងក្រោម មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះអនុក្រឹត្យស្ដីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ដែលប្រកាសឱ្យប្រើ កាលពីថ្ងៃចន្ទ ទី១៦ ខែកុម្ភៈនេះ និងស្នើសុំឱ្យរាជរដ្ឋាភិបាលនិរាកណ៍អនុក្រឹត្យនេះឱ្យបានឆាប់រហ័ស ។ នៅពេលដែលត្រូវបានអាជ្ញាធរដ្ឋអនុវត្តអនុក្រឹត្យនេះ នឹងរឹតត្បិតទៅលើសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ជាពិសេសសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិក្នុងការទទួលបានព័ត៌មាន សិទ្ធិលើឯកជនភាព ភាពប្រកួតប្រជែងនៃក្រុមហ៊ុនផ្ដល់សេវាអ៊ីនធឺណិតនៅកម្ពុជា ដែលនេះអាចនឹងប៉ះពាល់យ៉ាងខ្លាំងដល់ការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ។

មាត្រាមួយចំនួននៃអនុក្រឹត្យខាងលើ ជាពិសេសមាត្រា៦ មាត្រា១២ មាត្រា១៣ និងមាត្រា១៤ មានខ្លឹមសារទូលំទូលាយ និងមិនសូវច្បាស់លាស់ និងមានលក្ខណៈរឹតត្បិតយ៉ាងខ្លាំងដល់សិទ្ធិសេរីភាពជាមូលដ្ឋានរបស់ពលរដ្ឋដែលប្រើប្រាស់អ៊ីនធឺណិត និងភាពប្រកួតប្រជែងនៃប្រតិបត្តិករទូរគមនាគមន៍នៅកម្ពុជា ។

ជាក់ស្ដែងមាត្រា៦ និងមាត្រា ១២ នៃអនុក្រឹត្យនេះបានដាក់កំហិតតួនាទីដល់ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ ឱ្យសហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងនិយ័តករទូរគមនាគមន៍កម្ពុជា និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត ក្នុងការចាត់វិធានការទប់ស្កាត់ និងកាត់ផ្ដាច់ចោលរាល់ការតភ្ជាប់បណ្ដាញទាំងឡាយដែលប៉ះពាល់ដល់ចំណូលជាតិ សុវត្ថិភាព របៀបរៀបរយសណ្ដាប់ធ្នាប់សង្គម សីលធម៌ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់សង្គម។ អត្ថន័យនៃមាត្រានេះ មានលក្ខណៈទូលាយ និងស្រពិចស្រពិល ដែលអាចត្រូវបានអាជ្ញាធររដ្ឋបកស្រាយ និងអនុវត្តទៅលើ សកម្មជនសិទ្ធិមនុស្ស ពលរដ្ឋសហគមន៍មូលដ្ឋាន ឬ ពលរដ្ឋ ឬក្រុមមនុស្សទាំងឡាយណាដែលបញ្ចេញមតិរិះគន់រាជរដ្ឋាភិបាលតាមបណ្ដាញអ៊ីនធឺណិត និងបណ្ដាញទំនាក់ទំនងសង្គម ដោយចាត់ទុកថាសកម្មភាពរិះគន់ទាំងនោះ "ប៉ះពាល់ដល់របៀបរៀបរយសណ្ដាប់ធ្នាប់សង្គម សីលធម៌ វប្បធម៌ ប្រពៃណី និងទំនៀមទំលាប់សង្គម" ។

ក្រៅពីនេះ ខ្លឹមសារដ៏ទូលំទូលាយនៅក្នុងមាត្រានេះ ក៏នឹងផ្ដល់អំណាចឱ្យអាជ្ញាធរមានសមត្ថកិច្ចងាយស្រួលក្នុងការចាត់វិធានការរឹតត្បិតលើការទទួលបានព័ត៌មាននៅលើបណ្ដាញអ៊ីនធឺណិត ឬបិទ

គេហទំព័រ ឬបណ្តាញសង្គមណា ដែលអាជ្ញាធររដ្ឋយល់ថាមានគំនិតផ្ទុយ ឬរិះគន់រាជរដ្ឋាភិបាល ទោះជាគេហទំព័រ ឬបណ្តាញសង្គមទាំងនោះ បានផ្តល់ព័ត៌មានដែលសាធារណៈមតិយល់ថាជាព័ត៌មានឯករាជ្យក៏ដោយ ។ វិធានការតាមរយៈអនុក្រឹត្យនេះ អាចនឹងរំលោភទៅលើសិទ្ធិក្នុងការទទួលបានព័ត៌មាន ដែលរាជរដ្ឋាភិបាលធ្លាប់បានបង្ហាញឆន្ទៈថានឹងគោរពតាមរយៈសេចក្តីព្រាងច្បាប់ស្តីពីការទទួលបានព័ត៌មាន និងវេទិកាពិគ្រោះយោបល់ជាច្រើនលើកច្រើនសារទៅលើសេចក្តីព្រាងច្បាប់នោះកន្លងមកហើយ ។

លើសពីនេះ មាត្រា១៤ បានតម្រូវឱ្យប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិរក្សាទុកកំណត់ត្រាបច្ចេកទេស និងតារាងបែងចែកការផ្តល់អាសយដ្ឋានអាយភីនិងការកំណត់ផ្លូវនៃត្រាហ្វិកឆ្លងកាត់នៅច្រកទ្វារអ៊ីនធឺណិតជាតិសម្រាប់រយៈពេល១២ខែ ។ នេះមានន័យថា ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិអាចដឹងអំពីសកម្មភាពរបស់មនុស្សគ្រប់គ្នា ដែលប្រើប្រាស់អ៊ីនធឺណិតនៅក្នុងប្រទេសកម្ពុជា រួមទាំងប្រវត្តិព័ត៌មានដែលពួកគេស្វែងរក ហើយនិងគេហទំព័រដែលមិនមានកូដនីយកម្ម (unencrypted search history) ដែលពួកគេចូលមើល រហូតដល់មួយឆ្នាំពេញ ។ ការរក្សាទុករយៈពេលយូរហួសហេតុនេះ នឹងរំលោភទៅលើសិទ្ធិលើឯកជនភាពរបស់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់អ៊ីនធឺណិត និងបណ្តាញសង្គមនៅកម្ពុជា ។

ជាមួយគ្នានេះដែរ យើងបានពិនិត្យឃើញថាការបង្កើតអនុក្រឹត្យស្តីពីច្រកទ្វារអ៊ីនធឺណិតជាតិនឹងជះឥទ្ធិពលអាក្រក់ដល់សេដ្ឋកិច្ច ជាពិសេសលើភាពប្រកួតប្រជែងតាមប្រព័ន្ធអេឡិចត្រូនិកដែលកំពុងរីកចម្រើននៅកម្ពុជា ។ ការឆ្លងកាត់ច្រកទ្វារអ៊ីនធឺណិតជាតិតែមួយពីគ្រប់ប្រតិបត្តិការរបស់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតទាំងអស់ អាចនឹងធ្វើឱ្យប៉ះពាល់ដល់ការប្រកួតប្រជែងក្នុងការផ្តល់សេវាអ៊ីនធឺណិតល្បឿនលឿនពីគ្រប់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ដល់ប្រជាពលរដ្ឋកម្ពុជា ។

លើសពីនេះទៅទៀត ការបង្កើតច្រកទ្វារតែមួយបែបនេះ ក៏អាចបង្កើតឱ្យមានការប្រកួតប្រជែងមិនស្មោះត្រង់រវាងក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតផងដែរ ។ ការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិនេះ ត្រូវបានគេជឿជាក់ថា អាចផ្តល់សិទ្ធិអំណាចដល់អាជ្ញាធររដ្ឋក្នុងការអន្តរាគមន៍ទៅលើប្រតិបត្តិការនៃការផ្តល់សេវាអ៊ីនធឺណិតរបស់ក្រុមហ៊ុនអ៊ីនធឺណិតឯកជន ដោយអាចបង្កភាពងាយស្រួល ឬអនុញ្ញាតឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតណាមួយដែលមានទំនាក់ទំនងល្អជាមួយអាជ្ញាធររដ្ឋ និងអ្នកមានអំណាច ផ្តល់នូវសេវាអ៊ីនធឺណិតល្បឿនលឿនជាងក្រុមហ៊ុនសេវាអ៊ីនធឺណិតដទៃទៀត ។

យើងបារម្ភថាអនុក្រឹត្យនេះនឹងក្លាយជាឧបសគ្គដល់ក្រុមហ៊ុនបច្ចេកវិទ្យានិងបង្កើតភាពមិនប្រាកដប្រជាដែលអាចបណ្តាលឱ្យអ្នកវិនិយោគទុនចាកចេញពីទីផ្សារបច្ចេកវិទ្យានៅកម្ពុជា ។ បន្ថែមលើនេះ

ប្រសិនបើក្រុមហ៊ុនឯកជនត្រូវបានបង្ខំឱ្យចាកចេញមែន នោះបន្ទុកនៃការបង់ថ្លៃលើសេវានៃការប្រើប្រាស់អ៊ីនធឺណិតនឹងកើនឡើង នឹងធ្លាក់មកលើប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ ហើយគុណភាពនៃសេវាអ៊ីនធឺណិតនឹងធ្លាក់ចុះ ។ យើងខ្ញុំទទូចឱ្យរាជរដ្ឋាភិបាលនិរាកណ៍អនុក្រឹត្យនេះឱ្យបានឆាប់រហ័ស ដើម្បីធានាថា សេរីភាពមូលដ្ឋាន និងធានាប្រសិទ្ធភាពនៃការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋខ្មែរ និងបានជាប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ នឹងត្រូវបានគោរពដោយស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ៕

**<u>ស្ថាប័នដែលបានចូលរួមមានៈ</u>**

1. សហគមន៍ដីធ្លី ១៩៧ (កោះកុង)
2. សកម្មភាពដើម្បីបរិស្ថាន និងសហគមន៍ (AEC)
3. សហគមន៍ជនជាតិដើមភាគតិចអារ៉ែង (កោះកុង)
4. សហគមន៍ដីធ្លីអណ្ដូងត្របែក (ស្វាយរៀង)
5. សហគមន៍បឹងប្រាំ (បាត់ដំបង)
6. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)
7. អង្គការព្រះពុទ្ធសាសនាសម្រាប់សន្តិភាព (BPO)
8. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
9. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា អាដហុក (ADHOC)
10. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
11. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
12. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)
13. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
14. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)
15. បណ្ដាញយុវជនកម្ពុជា (CYN)
16. បណ្ដាញព្រះសង្ឃយុវជនកម្ពុជា (CYMN)
17. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
18. សហគមន៍សាមគ្គីចេកមាស (ស្វាយរៀង)
19. សហគមន៍ដីធ្លីដីខក្រោម (កោះកុង)
20. សហគមន៍ដីធ្លីដីខលើ (កោះកុង)

21. សហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ (រតនគីរី)
22. បណ្តាញកសាងសន្តិភាពសហគមន៍ (CPN)
23. អង្គការសមធម៌កម្ពុជា (EC)
24. សហគមន៍ហោងសំណំ (កំពង់ស្ពឺ)
25. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
26. បណ្តាញព្រះសង្ឃ ឯករាជ្យដើម្បីយុត្តិធម៌សង្គម (IMNSJ)
27. សហគមន៍ឃ្លាំងទឹក៧៨ (សៀមរាប)
28. សហគមន៍ជនជាតិភាគតិចគួយ (ព្រះវិហារ)
29. សហគមន៍ដីធ្លីខេត្តប៉ៃលិន
30. សហគមន៍ឡពាង (កំពង់ឆ្នាំង)
31. សហគមន៍មានជ័យ (ស្វាយរៀង)
32. សហគមន៍អូរល្ហីព្រេង (បាត់ដំបង)
33. អង្គការស្ពានសន្តិភាព (PBO)
34. សហគមន៍ដីធ្លីភូមិផ្សារកណ្តាល (បន្ទាយមានជ័យ)
35. សហគមន៍ដីធ្លីភូមិសិលាខ្មែរ (បន្ទាយមានជ័យ)
36. អង្គការពន្លកខ្មែរ (PKH)
37. បណ្តាញសហគមន៍ព្រៃឡង់ (PLCN)
38. អង្គការគាំទ្របច្ចេកវិទ្យានៅជនបទក្នុងប្រទេសកម្ពុជា (RCTSO)
39. សមាគមជាងត្នោត (STT)
40. សហគមន៍ធនធានព្រៃឈើស្ទឹងខ្សាច់ស (កំពង់ឆ្នាំង)
41. សហគមន៍ដីធ្លីតានួន (កោះកុង)
42. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)
43. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
44. អង្គការតម្លាភាពកម្ពុជា(TIC)
45. អង្គការអាក់សិនអេតកម្ពុជា (ActionAid Cambodia)
46. សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
47. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)

48. សម្ព័ន្ធសហជីពកម្ពុជា (CATU)

49. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)

50. សហព័ន្ធសហជីពឯករាជ្យ (INTUFE)

51. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ (LRSU)

52. សហព័ន្ធសហជីពសេរីឯករាជ្យ (FUFI)

53. សហពន្ធ័សហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC)

54. សហជីពឯករាជ្យកំលាំងសាមគ្គីកម្មករ (WSSIU)

55. សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (C.CAWDU)

56. គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)

57. ក្លាហាន (Klahaan)

58. វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ (API)

59. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព (PDP Center)

60. សហព័ន្ធអ្នកសារព័ត៌អន្តរជាតិ (IFJ)

61. ក្លឹបអ្នកសារព័ត៌មានបរទេសនៃកម្ពុជា (OPCC)

62. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)